ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយមូលបត្រអាចជួញដូរបាន ដែលគ្រឹះស្ថានធនាគារអាចនឹងប្រើប្រាស់ចាប់ពីថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៣ នេះតទៅ ។ ការចេញផ្សាយនេះគឺជាផ្នែកមួយនៃកំណែទម្រង់ និងការអភិវឌ្ឍជាបន្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០ របស់រាជរដ្ឋាភិបាល ក្នុងគោលបំណង (i) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ នៅលើមូលដ្ឋានប្រកប ដោយសុវត្ថិភាព (ii) ផ្តល់ដល់គ្រឹះស្ថានធនាគារនូវឧបករណ៍មួយថ្មីទៀតសម្រាប់គ្រប់គ្រងសន្ទនីយភាពជាបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់ដែលមានស្រាប់ និង (iii) បង្កើតឧបករណ៍នយោបាយរូបិយវត្ថុសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព ។ មូលបត្រអាចជួញដូរបាននេះ មានរូបភាពជាប័ណ្ណប្រាក់បញ្ញើអាចជួញដូរបាន (Negotiable Certificate of Deposits) និងជាឧបករណ៍ហិរញ្ញវត្ថុរយៈកាលខ្លីដែលម្ចាស់មូលបត្រអាចប្រើប្រាស់ដើម្បីដោះស្រាយកង្វះខាតសន្ទនីយភាពបណ្តោះអាសន្ន ក្រោមរូបភាពជាការលក់ ដាក់បញ្ចាំ និងធ្វើជាវត្ថុធានាការខ្ចីចងការ ឬប្រតិបត្តិការទទួលទិញវិញ (Repurchase Agreement) ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៣

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧